ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៦៨/១៤-អ៊ី អិម ប៊ី ដែលកូវី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ហែម ហួណារិទ្ធ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេង ថុង**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន អ៊ី អិម ប៊ី ដែលកូវី**

អាសយដ្ឋាន ៖ ភូមិចាក់ជ្រូក សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៨៣១ ០៦១ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖ គ្មាន

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សហព័ន្ធសហជីពកម្មករកម្ពុជា**

- **សហជីពកម្មករកម្ពុជាពេចចក្រ ឥ.វ៉ាន អ៊ីមប្រូយឌើរី ខូអិលធីឌី**

អាសយដ្ឋាន ៖ ផ្ទះលេខ៣០សេ ផ្លូវលេខ៣៧១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៦១៦ ៥៩៨ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

- លោក ហួរ ពៅ មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយបន្ថែមចំនួន ២០០០ រៀល។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ជូនលើសពីច្បាប់បានទេ គឺក្រុមហ៊ុនអនុវត្តទៅតាមសេចក្តីជូនដំណឹង របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីពីលទ្ធផលនៃការដោះស្រាយវិវាទរួម លេខ ៣២២ កប/អក/វក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងរបស់សហព័ន្ធសហជីពកម្មករកម្ពុជា ស្តីពីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញចុះធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៧ ចំណុច លើការទាមទារចំនួន ០៨ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ៣២២ កប/អក/វក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត

មកសវនាការ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ វេលាម៉ោង ២ រសៀល។ ភាគីកម្មករនិយោជិតមានវត្តមាននៅថ្ងៃសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែភាគីនិយោជកមិនបានមានវត្តមាននៅក្នុងសវនាការតាមការអញ្ជើញទេ។

នៅពេលចាប់ផ្តើមសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទងនឹងចំណុចវិវាទដែលនៅសល់នេះ ប៉ុន្តែមិនទទួលបានការព្រមព្រៀង ឬដកចំណុចវិវាទពីភាគីកម្មករនិយោជិតទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចវិវាទមិនសះជា ០១ ចំណុច គឺ ចំណុចវិវាទទី ១។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ១៥៦២ កប/អក/វក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ របស់ប្រធាននាយកដ្ឋានវិវាទការងារជម្រាបមក លោកប្រធានសហជីពកម្មករកម្ពុជារោងចក្រ ជេ.វ៉ាន អឹមប្រយឌើរី ខូអិលធីឌី ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី។

២- លិខិតលេខ ០២៤/១៣ កប ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្មករកម្ពុជារោងចក្រ ជេ.វ៉ាន អឹមប្រយឌើរី ខូអិលធីឌី ត្រូវបានចុះបញ្ជិកាពេញលក្ខណៈច្បាប់នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មករកម្ពុជារោងចក្រ ជេ.វ៉ាន អឹមប្រយឌើរី ខូអិលធីឌី ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣។

៤- លិខិតលេខ ៤០៨០/១៤ សសកក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ របស់សហព័ន្ធសហជីពកម្មករកម្ពុជាគោរពជូន លោកនាយកក្រុមហ៊ុន ប៉ាក់សម្លៀកបំពាក់ អ៊ី អិម ប៊ី ដែលកូរី (ខេមបូឌា) ស្តីពីជូនដំណឹងអំពីសមាសភាពជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពកម្មករកម្ពុជារោងចក្រ ប៉ាក់សម្លៀកបំពាក់ អ៊ី អិម ប៊ី ដែលកូរី (ខេមបូឌា)។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អ៊ី អិម ប៊ី ដែលកូរី លេខ ៣២២ កប/



៧

អក/វក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤។

២- កំណត់ហេតុស្តីពីការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន អ៊ី អិម ប៊ី ដែលកូរី ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតលេខ ៣១០ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក លោកនាយកក្រុមហ៊ុន អ៊ី អិម ប៊ី ដែលកូរី ស្តីពីការជ្រើសរើសក្រុមអាជ្ញាកណ្តាល។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសមាគមនិយោជក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣៥០ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣៥១ កប/អក/វក/លកអ. ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៤។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- យោងតាមរបាយការណ៍មិនសះជា លេខ ៣២២ កប/អក/វក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមហ៊ុន អ៊ី អិម ប៊ី ដែលកូរី គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ដែលមានជួលកម្មករនិយោជិតសរុបចំនួន ១៩០ នាក់។
- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានអះអាងថា ក្រុមហ៊ុននេះមានការប្តូរឈ្មោះពី ជេ វ៉ាន អ៊ីមប្រយឌើរី ខូលអិលធីឌី ទៅឈ្មោះ អ៊ី អិម ប៊ី ដែលកូរី វិញ។ ដោយភាគីនិយោជកមិនមានវត្តមាននៅក្នុងសវនាការ ដើម្បីលើកអំណះអំណាងផ្សេងពីនេះ ហើយក៏មិនផ្តល់ជាភស្តុតាងផ្ទុយជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងទទួលយកអំណះអំណាងរបស់ភាគីកម្មករនិយោជិត អំពីការផ្លាស់ប្តូរឈ្មោះក្រុមហ៊ុនពី ជេ វ៉ាន អ៊ីមប្រយឌើរី ខូលអិលធីឌី ទៅឈ្មោះ អ៊ី អិម ប៊ី ដែលកូរី ថា ជាបានការ។

- សហជីពកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ជេ.វ៉ាន អ៊ីមប្រយអឺរី ខូអិលធីឌី គឺជាដើមបណ្តឹង ដែលបានទទួលវិញ្ញាបនប័ត្រចុះបញ្ជិកាសហជីព លេខ ២៧៥៦ ក.ប/វក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ និងលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពអាណត្តិថ្មី លេខ ១៥៦២ កប/អក/វក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ ពីនាយកដ្ឋានវិវាទការងារ ដែលរួមមាន៖ (១) លោក សាញ់ គី ជាប្រធាន, (២) លោក សេក សំរ៉ុង ជាអនុប្រធាន និង(៣) លោក ចេវ សុខេង ជាលេខាធិការ។ សហជីពនេះ មិនមានភាពជាតំណាងបំផុតប្រចាំក្រុមហ៊ុនទេ។
- មានកម្មករនិយោជិតចំនួន ០៨ នាក់ បានផ្ទេរសិទ្ធិជូនប្រធានសហព័ន្ធសហជីពកម្មករកម្ពុជា ឱ្យធ្វើជាអ្នកតំណាង ក្នុងការដោះស្រាយវិវាទនៅក្នុងសំណុំរឿងនេះ តាមរយៈលិខិតពឹងពាក់ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ដែលក្នុងនោះរួមមានឈ្មោះ (១)អ៊ុង តុលា, (២)សេក សំរ៉ុង, (៣)ឡា សុភក្ត្ត ,(៤)សេក សីហា, (៥)ផល មករា ,(៦) ប៊ាន លក្ខិណា ,(៧)កែវ វ៉ន និង (៨)សាញ់ គី។
- នៅថ្ងៃសវនាការ មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា ចំនួន ០១ នាក់ គឺ លោក ហួរ ពៅ ដែលបានមកចូលរួមសវនាការ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ ។

**ចំណុចវិវាទ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ដល់កម្មករដែលស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោង ចំនួន ៣០០០ រៀល***

- ការអនុវត្តសព្វថ្ងៃនៅក្នុងក្រុមហ៊ុន គឺនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ដល់កម្មករនិយោជិតដែលបានស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោង ក្នុងមួយម៉ោង ចំនួន ១០០០ រៀល។ ពោល គឺ ៖
    - ចាប់ពីម៉ោង ៤៖ ០០ នាទី រសៀល ទៅ ៦៖០០ នាទី យប់ ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មានចំនួន ២០០០ រៀល។
    - ចាប់ពីម៉ោង ៤៖០០ នាទី រសៀល ទៅ ៧៖០០ នាទី យប់ ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មានចំនួន ៣០០០ រៀល។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា និយោជកបានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង យ៉ាងតិចណាស់ចំនួន ២០០០ រៀល ចំពោះកម្មករនិយោជិតណាដែលបានស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោង។
- នៅពេលសវនាការ ភាគីកម្មករនិយោជកបានបញ្ជាក់ការទាមទារថា ស្នើសុំឱ្យនិយោជកបន្ថែមប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ពេលដែលពួកគាត់ស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងចំនួន ១០០០ រៀល ក្នុងមួយម៉ោង។ ពោលគឺមានន័យថា៖
    - ចាប់ពីម៉ោង ៤៖ ០០ នាទី រសៀល ទៅ ៦៖០០នាទី យប់ គឺស្នើសុំឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០ រៀល។
    - ចាប់ពីម៉ោង ៤៖ ០០ នាទី រសៀល ទៅ ៧៖០០ នាទី យប់ គឺសុំឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៦០០០ រៀល។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា ៖

THE ARBITRATION COUNCIL

- មានក្រុមហ៊ុនផ្សេងទៀតបានផ្ដល់ប្រាក់ថ្លៃបាយធ្វើការបន្ថែម ចំនួន ៥០០០ រៀល អំឡុងពេលដែលកម្មករនិយោជិតបានស្ម័គ្រធ្វើការបន្ថែមម៉ោង ដូចជាក្រុមហ៊ុន ប៊ីរី ជាដើម ។
- និយោជកផ្ដល់ឱ្យ ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង យ៉ាងតិចណាស់ចំនួន ២០០០ រៀល នៅពេលដែលកម្មករនិយោជិតបានស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោង គឺមានចំនួនតិចតួចណាស់ ដែលមិនអាចទ្រទ្រង់ជីវភាពរបស់ពួកគាត់បានទេ ។ ជាក់ស្ដែង សម្ល និងបាយដែលកម្មករនិយោជិតត្រូវបរិភោគ គឺមានតម្លៃចាប់ពី ៣០០០ រៀល ទៅ៥០០០ រៀល ក្នុងមួយពេល ។

**ហេតុផលនៃសេចក្ដីសម្រេច ÷**

មុននឹងពិចារណាចំណុចទាមទាររបស់ភាគីកម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្ដាលត្រូវពិចារណាដូចតទៅ ៖

**១)ភាពតំណាងនៃដើមបណ្ដឹង ៖**

នៅក្នុងសំណុំរឿងនេះ មានកម្មករនិយោជិតចំនួន ០៨ នាក់ បានផ្ទេរសិទ្ធិជូនប្រធានសហព័ន្ធសហជីពកម្មករ កម្ពុជា ឱ្យធ្វើជាអ្នកតំណាងក្នុងការដោះស្រាយវិវាទនៅក្នុងសំណុំរឿងនេះ តាមរយៈលិខិតពឹងពាក់ចុះថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណាដូចខាងក្រោម ៖

ប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលចែងថា៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល ដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ "* ។

យោងតាមខ្លឹមសារប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ខាងលើ ក្រុមប្រឹក្សអាជ្ញាកណ្ដាលយល់ឃើញថា ពាក្យថា *"ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ"* មានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេងតំណាងឱ្យខ្លួនក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្ដាលបាន លុះត្រាបុគ្គលនោះទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ *១៦១/០៩-សិប្បកម្មព្រែកគ្រែង និងលេខ ៤៣/១០-ម៉ីង ជៀន និងលេខ ១៤២/១៣-ឌី & អិល* អាល់ធីមេត (ខេមបូឌា) ) ។

យោងតាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា មានថ្នាក់ដឹកនាំសហជីពកម្មករកម្ពុជាមូលដ្ឋាន បានធ្វើការផ្ទេរសិទ្ធិទៅឱ្យ ប្រធានសហព័ន្ធសហជីពកម្មករកម្ពុជា ដើម្បីតំណាងក្នុងសំណុំរឿងនេះ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សហព័ន្ធសហជីពកម្មករកម្ពុជាក៏អាចតំណាងឱ្យសមាជិកនៃសហជីពមូលដ្ឋានបានផងដែរ ។

**២) តើក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចបន្តដំណើរការបានដែរ ឬទេ នៅពេលដែលភាគីនិយោជកអវត្តមាន ៖**

ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលចែងថា៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមក*

*បង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ ។"*

យោងតាមខ្លឹមសារនៃប្រការ ២១ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ខាងលើនេះ នៅក្នុងសំណុំរឿងមុនៗ នៅពេលដែលភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវ តែបែរជាខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចបន្តដំណើរការរបស់ខ្លួន ដោយធ្វើការបើកសវនាការកំបាំងមុខភាគីដែលអវត្តមាននោះ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៣/០៤- គួង ហុង, លេខ ៦៣/០៤-សាញ វ៉ែល, លេខ ១៤៨/០៧-ប៉ាយ ហឺ, លេខ ៩៩/០៩ - យឹង ឡែន, លេខ ១៧៣/១១-ជិន អ៊ីង និង លេខ ៣៤/១២-ស៊ុន ឆាង ស៊ុន*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជក និងភាគីកម្មករនិយោជិតបានទទួលការអញ្ជើញត្រឹមត្រូវ ឱ្យចូលរួមសវនាការពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែ នៅថ្ងៃសវនាការមានតែភាគីកម្មករនិយោជិតទេ ដែលបានចូលរួមសវនាការតាមការអញ្ជើញ ។ ចំណែកឯភាគីនិយោជកមិនបានចូលរួមសវនាការតាមការអញ្ជើញទេ ។ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ វេលាម៉ោង ២ និង ១៥ នាទី រសៀល មន្ត្រីលេខាធិដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទូរស័ព្ទទៅភាគីនិយោជក ដោយគាត់បានប្រាប់មកមន្ត្រីលេខាធិដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលវិញថា មិនមានអ្នកណាពីក្រុមហ៊ុនអាចចូលរួមក្នុងសវនាការ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ ទេ ពីព្រោះថា អ្នកទទួលខុសត្រូវក្នុងសំណុំរឿងនេះមានការរវល់ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការលើកឡើងរបស់ភាគីនិយោជកពុំបានបញ្ជាក់មូលហេតុត្រឹមត្រូវ ក្នុងការមិនចូលរួមសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបន្តដំណើរការរបស់ខ្លួន ដោយអវត្តមានភាគីនិយោជក ។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបន្ថែមប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ពេលដែលពួកគាត់ស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង ចំនួន ១០០០ រៀល ក្នុងមួយម៉ោង ពោលគឺមានន័យថា៖ (១)ករណីកម្មករនិយោជិតស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោងចាប់ពីម៉ោង ៤៖ ០០ នាទី រសៀល ទៅ ៦៖០០នាទីយប់ គឺស្នើសុំឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០ រៀល ឬ(២)ករណីកម្មករនិយោជិតស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោងចាប់ពីម៉ោង ៤៖០០ នាទី រសៀល ទៅ៧៖០០ នាទីយប់ គឺសុំឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៦០០០ រៀល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើកម្មករនិយោជិតមានសិទ្ធិទាមទារឱ្យនិយោជកបន្ថែមប្រាក់ថ្លៃបាយធ្វើការថែមម៉ោង ចំនួន ១០០០រៀល ក្នុងមួយម៉ោង ដែរ ឬទេ?

តាមអង្គហេតុក្នុងសំណុំរឿងនេះ គឺនិយោជកបានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង យ៉ាងតិចណាស់ចំនួន ២០០០ រៀល ចំពោះកម្មករនិយោជិតណាដែលបានស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោង ។ ភាគីកម្មករនិយោជិតបានទាម

ទារឱ្យនិយោជកបន្ថែមប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ពេលដែលពួកគាត់ស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង ចំនួន ១០០០ រៀល ក្នុងមួយម៉ោង។ ពោលគឺមានន័យថា (១)ករណីកម្មករនិយោជិតស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោងចាប់ពីម៉ោង ៤៖ ០០ នាទី រសៀល ទៅ ៦៖០០នាទី យប់ គឺស្នើសុំឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០ រៀល ឬ (២)ករណីកម្មករនិយោជិតស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោងចាប់ពីម៉ោង ៤៖ ០០ នាទី រសៀល ទៅ ៧៖០០ នាទី យប់ គឺសុំឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៦០០០ រៀល។

ចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា៖ *"កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀលក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ"*។

តាមខ្លឹមសារនៃចំណុចទី២ នៃសេចក្តីជូន ដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ខាងលើនេះ កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជកត្រូវទទួលបានប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០ (ពីរពាន់) រៀលក្នុងមួយថ្ងៃ ដោយមិនកំណត់ថា ធ្វើការបន្ថែមម៉ោងចំនួនប៉ុន្មានម៉ោងទេ។*(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៨២/១៣-ស៊ីណូ ហ្គាមេន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២)*

តាមអង្គហេតុខាងលើនេះ គឺនិយោជកបានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងយ៉ាងតិចណាស់ ចំនួន ២០០០ រៀល ចំពោះកម្មករនិយោជិតណា ដែលបានស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោង។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកបានអនុវត្តតាមតាមខ្លឹមសារនៃចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ខាងលើហើយ។

ពាក់ព័ន្ធនឹងការទាមទារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានច្បាប់ បទប្បញ្ញត្តិការងារ កិច្ចព្រមព្រៀង អនុសញ្ញារួមណាមួយ រវាងនិយោជក និងភាគីកម្មករនិយោជិត ការអនុវត្តកន្លងមក ឬបទបញ្ជាផ្ទៃក្នុង ដែលចែងអំពីកាតព្វកិច្ចរបស់និយោជក ក្នុងការបន្ថែមប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ១០០០ រៀល ក្នុងមួយម៉ោង ដល់កម្មករនិយោជិត ដែលស្ម័គ្រចិត្តមកធ្វើការបន្ថែមម៉ោងទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនេះជាវិវាទអំពីផលប្រយោជន៍។

ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាដូចខាងក្រោម៖

កថាខណ្ឌទី២ នៃមាត្រា ៩៦ នៃច្បាប់ស្តីពីការងារចែងថា៖ *"អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀង ជាលាយលក្ខណ៍អក្សរ ដែលទាក់ទងដល់បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុង មាត្រា ៩៦ កថាខ័ណ្ឌទី១ អនុសញ្ញារួមត្រូវធ្វើឡើង ដោយព្រមព្រៀងគ្នារវាង៖*

*ក. មួយចំណែក គឺនិយោជកម្នាក់ និយោជកមួយក្រុម ឬអង្គការមួយឬអង្គការច្រើនតំណាងឱ្យនិយោជក*

*ខ. មួយចំណែកទៀតគឺអង្គការសហជីពមួយ ឬអង្គការសហជីពច្រើនតំណាងឱ្យកម្មករនិយោជិត។...។"*

លើសពីនេះ ប្រការ ៩ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជា

តំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ចែងថា ៖ *"សហជីពដែលមានភាពជាតំណាងបំផុត មានសិទ្ធិស្នើសុំឱ្យនិយោជកធ្វើការចរចា អំពីអនុសញ្ញារួមដែលអនុវត្តចំពោះ កម្មករនិយោជិតទាំងអស់ ដែលសហជីពនោះតំណាងឱ្យ ក្នុងករណីនេះ និយោជកមានកាតព្វកិច្ច ត្រូវតែធ្វើការចរចាជាមួយសហជីព"*។

យោងតាមមាត្រា ៩៦ នៃច្បាប់ស្តីពីការងារ និងប្រការ៩ នៃប្រកាស ៣០៥/០១ ខាងលើ ជាទូទៅចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុត របស់សហជីពដែលជាភាគីវិវាទ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីព ផ្តល់សិទ្ធិតាមផ្លូវច្បាប់ដល់សហជីព ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងក្នុងការនាំសំណុំរឿងវិវាទអំពីផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។

ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ចែងថា ៖ *"សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលដោះស្រាយវិវាទផលប្រយោជន៍ នឹងត្រូវមកជំនួសអនុសញ្ញា រួម និង មានប្រសិទ្ធភាពអនុវត្តរយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នា លើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ "*។

យោងតាមខ្លឹមសារនៃប្រការ ៤៣ ខាងលើ សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីផលប្រយោជន៍ នឹងក្លាយជាអនុសញ្ញារួមដែលអនុវត្តទៅលើកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតទាំងអស់ បាត់បង់សិទ្ធិក្នុងការទាមទារលើវិវាទដែលទាក់ទងនឹងផលប្រយោជន៍នាពេលអនាគត ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយវិវាទអំពីផលប្រយោជន៍បាន លុះត្រាតែសហជីពដែលទាមទារនាំយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងនៅក្នុងសហគ្រាស ឬសហជីពច្រើនរួមគ្នាទៅមានចំនួនសមាជិកលើសពីពាក់កណ្តាលនៃកម្មករនិយោជិតនៅក្នុងសហគ្រាស *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៨១/០៤-អេវើហ្គ្រីន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤ និងលេខ ៩៨/០៤-ហ្គ្រេត យូនៀន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣ )*។

នៅក្នុងសំណុំរឿងលេខ ១៦៩/១១-ហ៊្វូធៀនធីរ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាវិវាទអំពីផលប្រយោជន៍ ដោយសារសហជីពដែលនាំវិវាទការងារនោះមក ជាសហជីព ដែលមិនមានភាពតំណាងបំផុតនៅក្នុងរោងចក្រ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០២/១១-ពូយៀន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២ និងលេខ ៦៦/១១-អ៊ិនហានស៊ុង ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ )* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ។

THE ARBITRATION COUNCIL

ក្នុងសំណុំរឿងនេះ សហជីពកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ជាដើមបណ្តឹង ដែលបានផ្ទេរសិទ្ធិឱ្យប្រធានសហព័ន្ធសហជីពកម្មករកម្ពុជាមកតំណាងក្នុងសំណុំរឿងនេះ ដែលមានមន្ត្រីសហព័ន្ធមកចូលរួមសវនាការ មិនមានភាពជាតំណាងបំផុតប្រចាំក្រុមហ៊ុនទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដើមបណ្តឹងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ ក្នុងការនាំវិវាទដែលទាក់ទងនឹងផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបន្ថែមប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ពេលដែលពួកគាត់ស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងចំនួន ១០០០ រៀល ក្នុងមួយម៉ោង។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ** ៖ បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបន្ថែមប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ពេលដែលពួកគាត់ស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង ចំនួន ១០០០ រៀល ក្នុងមួយម៉ោង។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **ហែម ហួណារិទ្ធ**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **អាំង អេង ថុង**

ហត្ថលេខា ៖ ------------------------------